ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ក្រសួងអភិវឌ្ឍន៍ជនបទ

ក្រសួងធនធានទឹក និង ឧតុនិយម

ក្រសួងមហាផ្ទៃ

ក្រសួងកិច្ចការនារី

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

# អេកូសន

## គោលដៅរួម

ចូលរួមកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើនប្រាក់ចំណូល ប្រចាំគ្រួសារ ជាពិសេស បង្កើនផលិតភាពកសិកម្ម និងការផ្តល់អំណាចគ្រប់គ្រង ដល់សហគមន៍មូលដ្ឋាន :

- ធ្វើអោយអត្រាភាពក្រីក្រស្ថិតក្នុងកំរិតទាប
- ធ្វើអោយសន្ទស្សន៍នៃភាពក្រីក្រកាន់តែប្រសើរឡើង
- ធ្វើអោយចំណាត់ថ្នាក់ទ្រព្យសម្បត្តិកាន់តែប្រសើរឡើង
- ធ្វើអោយប្រសើរនូវការផ្តល់អំណាចដល់សហគមន៍មូលដ្ឋាន
- ធ្វើអោយប្រសើរនូវការផ្តល់ភាពអង់អាចដល់ស្ត្រី
- កំរិតនៃការជឿជាក់កាន់តែប្រសើរឡើងនៅពេលអនាគត
- ចំណាកស្រុកតាមរដូវកាលមានការថយចុះ
- កង្វះស្បៀងប្រចាំខែមានការថយចុះ

## ក្រុមអនុវត្តគំរោង

- PMIS = ក្រុមគ្រប់គ្រងកម្មវិធី និងគាំទ្រស្ថាប័ន
- ALF = ក្រុមកសិកម្ម បសុសត្វ និងជលផល
- RIS = ក្រុមហេដ្ឋារចនាសម្ព័ន្ធជនបទ
- CGR = ក្រុមសហគមន៍ យេនឌ័រ និងអភិវឌ្ឍន៍ជនបទ
- SAL = ក្រុមសុវត្ថិភាពនៃការប្រើប្រាស់ដីធ្លី
- FPA = ក្រុមហិរញ្ញវត្ថុ លទ្ធកម្ម និងរដ្ឋបាល




## ការិយាល័យកម្មវិធី និងការិយាល័យប្រចាំខេត្តសៀមរាប

មន្ទីរកសិកម្មខេត្ត ភូមិវត្តដំណាក់ ឃុំសាលាកំរើក ស្រុកសៀមរាប ខេត្តសៀមរាប
**ប្រអប់សំបុត្រ:** ៩៣ ២៤១ សៀមរាបអង្គរ
**ទូរស័ព្ទ:** (០៦៣) ៩៦៥ ៤៧៨
**ទូរសារ:** (០៦៣) ៧៦១ ២៤៣
**អ៊ីម៉ែល:** siem.reap.office@ecosorn.org

## ការិយាល័យប្រចាំខេត្តបន្ទាយមានជ័យ :

មន្ទីរកសិកម្មខេត្ត ភូមិ២ ឃុំកំពង់ស្វាយ ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ
**ប្រអប់សំបុត្រ:** ០១០៥ BMC
**ទូរស័ព្ទ/ទូរសារ:** (០៥៤) ៧៤០ ៣៤៤
**អ៊ីម៉ែល:** banteay.meanchey.office@ecosorn.org

## ការិយាល័យប្រចាំខេត្តបាត់ដំបង :

មន្ទីរកសិកម្មខេត្ត ផ្លូវជាតិលេខ៥ ភូមិរំចេក ៤ ឃុំរតនៈ ស្រុកបាត់ដំបង ខេត្តបាត់ដំបង
**ប្រអប់សំបុត្រ:** ៤០៤ BTB
**ទូរស័ព្ទ/ទូរសារ:** (០៥៣) ៩៧០ ៣៩៨
**អ៊ីម៉ែល:** battambang.office@ecosorn.org

## ការិយាល័យសម្របសម្រួលភ្នំពេញ :

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
លេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ
បន្ទប់លេខ ១៩-២១ ជាន់ទី១ អាគារ AIDOC
**ទូរស័ព្ទ និង ហ្វាក់:** (០២៣) ២២៣ ៧៨៦
គេហទំព័រ: www.ecosorn.org




## គំរោងស្តារឡើងវិញលើវិស័យសេដ្ឋកិច្ច និង សង្គមកិច្ចនៅបណ្តាខេត្តនៃតំបន់ពាយ័ព្យ

**"ការអភិវឌ្ឍន៍លើវិស័យសេដ្ឋកិច្ច និង សង្គមកិច្ចនៅជនបទគឺជាការប្តេជ្ញាចិត្តរបស់យើង"**

គំរោងអេកូសន ត្រូវបានឧបត្ថម្ភដោយសហគមន៍អឺរ៉ុប និងរាជរដ្ឋាភិបាលកម្ពុជា



## ប្រវត្តិគំរោង

គំរោងស្តារឡើងវិញ លើវិស័យសេដ្ឋកិច្ច និង សង្គមកិច្ច នៅបណ្តាខេត្ត នៃតំបន់ពាយ័ព្យ ប្រទេសកម្ពុជា (អេកូសន) ដែលមានរយៈពេល ៥ឆ្នាំ បានទទួលមូលនិធិ ២៥.០០០.០០០ អឺរ៉ូ ពីសហគមន៍អឺរ៉ុប និង ១.០០០.០០០ អឺរ៉ូទៀតពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រតាមរយៈ ការបង្កើនប្រាក់ចំណូលក្នុងគ្រួសារ ការបង្កើនផលិតភាពកសិកម្ម និងការពង្រឹងសមត្ថភាពគ្រប់គ្រងដល់សហគមន៍មូលដ្ឋាន។ គំរោងនេះបានចាប់ផ្តើមដំណើរការជាផ្លូវការ នៅថ្ងៃទី ៧ ខែធ្នូ ឆ្នាំ ២០០៥ និងត្រូវបញ្ចប់នៅ ខែធ្នូ ឆ្នាំ ២០១០។

## សេចក្តីពណ៌នាអំពីគំរោង

បច្ចុប្បន្ន គំរោងត្រូវបានអនុវត្តដោយភ្នាក់ងារប្រតិបត្តិ គឺក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្មនៅតាមបណ្តាខេត្តគោលដៅ ចំនួន ៣ របស់គំរោងគឺ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ និង ខេត្តបាត់ដំបង ។

## វិធីសាស្ត្រគំរោង

គំរោងផ្តោតលើការអភិវឌ្ឍន៍ជនបទចំរុះ នៅតាមបណ្តាឃុំ/ភូមិគោលដៅ ដោយមានការចូលរួមពីអ្នកទទួលផល និងអ្នកពាក់ព័ន្ធនានា។ អេកូសន ជួយបង្កើតសេវាកម្មពេញលេញ ដែលទាក់ទងនឹងវិស័យកសិកម្ម បសុសត្វ ជលផល អភិវឌ្ឍន៍សហគមន៍ និងយេនឌ័រ ហេដ្ឋារចនាសម្ព័ន្ធជនបទ លទ្ធភាពនៃការប្រើប្រាស់ដីធ្លី ការផ្តល់កម្មសិទ្ធិដីធ្លី និងសេវាកម្មផ្សេងទៀត ដែលទាក់ទងនឹងការអភិវឌ្ឍន៍លើវិស័យសេដ្ឋកិច្ច និងសង្គមកិច្ចនៅក្នុងប្រទេសកម្ពុជា។ ជាពិសេស ធ្វើអោយការរស់នៅរបស់គ្រួសារកសិករក្រីក្រមានភាពប្រសើរឡើង តាមរយៈការអភិវឌ្ឍន៍ចំរុះនៃអន្តរសេវាកម្មពាណិជ្ជកម្ម លទ្ធភាពប្រើប្រាស់ផ្លូវថ្នល់ ទឹកស្អាត ការផ្តល់អំណាចគ្រប់គ្រងដល់សហគមន៍ ប្រព័ន្ធស្រោចស្រព ការផ្តល់កម្មសិទ្ធិដីធ្លី និងការបោសសំអាតគ្រាប់មីន និងសេវាកម្មផ្សេងទៀត។

## ក្រុមគោលដៅ

ក្រុមគោលដៅ នៅក្នុងស្រុកគោលដៅទាំង ១៤ ត្រូវបានកំណត់ដូចខាងក្រោម :

- ឃុំចំនួន ៤០ ក្នុងចំណោមឃុំទាំង ៩៦ = ៦៨.០០០គ្រួសារ
- កសិករចូលរួមក្នុងសកម្មភាពកសិកម្មមានចំនួន ៥៥.០០០គ្រួសារ = ២៨០.០០០ នាក់ ក្នុងនោះរួមមាន :
  - ⇒ កសិករចំនួន ១៤០.០០០នាក់ ខ្វះខាតស្បៀងបរិភោគ រយៈពេល ៤ ខែក្នុងមួយឆ្នាំ។
  - ⇒ កសិករចំនួន ៩០.០០០នាក់ គ្មានប្រាក់ចំណូលគ្រប់គ្រាន់ក្នុងការទិញស្បៀងបន្ថែមបន្ទាប់សំរាប់បរិភោគ។
  - ⇒ ស្ត្រីចំនួន ៦៧.០០០នាក់ មានអាយុពី ១៨ - ៦៤ឆ្នាំ
  - ⇒ យុវជន-យុវនារីចំនួន ២៥.០០០នាក់ មានអាយុពី ១៥ - ១៧ឆ្នាំ

| ខេត្តគោលដៅ | ស្រុកគោលដៅ | ចំនួនឃុំជ្រើសរើស |
|---|---|---|
| សៀមរាប | ស្រីស្នំ សូត្រនិគម ក្រឡាញ់ ជីក្រែង និង អង្គរធំ | ១៤ |
| បន្ទាយមានជ័យ | ភ្នំស្រុក ព្រះនេត្រព្រះ ថ្មពួក និង ស្វាយចេក | ១៣ |
| បាត់ដំបង | គាស់ក្រឡ សំពៅលូន មោងឬស្សី រតនមណ្ឌល និង បវេល | ១៣ |

### គោលដៅរបស់អេកូសន :

**ធ្វើប្រពលវប្បកម្ម ចំរុះ និងបង្កើនផលិតកម្មកសិកម្ម បសុសត្វ និង ជលផល:**

- គ្រួសារក្នុងតំបន់គោលដៅរបស់គំរោង មានការខ្វះខាតស្រូវចំនួន ២ខែក្នុងមួយឆ្នាំ
- ការទទួលយកបច្ចេកវិទ្យាកសិកម្ម ត្រូវបានលើកកំពស់ តាមរយៈអ្នកទទួលផលផ្ទាល់ ពី ២០ ទៅ ២៥% ។
- ជួយបង្កើនទិន្នផលស្រូវ ដល់អ្នកទទួលផលបានភ្លាមៗ (តាមរយៈស្រូវវស្សា) ពី ១,២ ដល់ ២,៤តោន ក្នុង១ហិកតា ។
- ជួយង្កើនទិន្នផលស្រូវដល់អ្នកទទួលផលបានភ្លាមៗ (តាមរយៈស្រូវស្រោចស្រព) ពី ១,៨ ដល់ ៣តោន ក្នុង១ហិកតា ។
- អត្រានៃការទទួលយកបច្ចេកវិទ្យាក្នុងការចិញ្ចឹមសត្វ និង ចិញ្ចឹមត្រី ត្រូវបានលើកកំពស់ ពី ១៥% ដល់ ២០%។
- ការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពលើផ្ទៃដី ១.២០០ហិកតា

**បង្កើតកាលានុវត្តភាពសេដ្ឋកិច្ច និងឱកាសការងារ:**

- បណ្តុះបណ្តាលវិជ្ជាជីវៈដល់ប្រជាពលរដ្ឋចំនួន ១.៨០០នាក់
- សូត្រ : ប្រជាពលរដ្ឋចំនួន ៤០០នាក់ចូលរួមក្នុងផលិតកម្មសូត្រ និងបង្កើតប្រាក់ចំណូលផ្សេងៗបន្ថែមទៀត។
- ទីផ្សារបន្លែ : បង្កើត និងគាំទ្រសមាគមអ្នកដាំដំណាំចំនួន ៣
- កែច្នៃត្រី : បង្កើតក្រុមកែច្នៃត្រីស្ត្រីចំនួន ១០

**ការផ្តល់អំណាចដល់សហគមន៍មូលដ្ឋាន:**

- ឃុំចំនួន៤០ ត្រូវបានពង្រឹងដោយគំរោង
- បុគ្គលិកមន្ទីរពាក់ព័ន្ធចំនួន ២៧០នាក់ត្រូវបានពង្រឹងសមត្ថភាព
- បង្កើតនិងពង្រឹងឡើងវិញសហគមន៍ និងសមាគមនៅក្នុងភូមិចំនួន ៩០
- កសិករចំនួន ២៧.០០០គ្រួសារយល់ដឹងពីអនាម័យទឹកស្អាត សុខភាព យេនឌ័រ និងបញ្ហាអគ្គិភ័យ។

**លើកកំពស់ការប្រើប្រាស់សេវាសង្គម និងទីផ្សារដែលមាន និងការធ្វើអោយប្រសើរឡើងនូវការប្រើប្រាស់ទឹកស្អាត :**

- កសាងចំណុចទឹកចំនួន ១.២០០កន្លែង
- សាងសង់បង្គន់អនាម័យចំនួន ៥០០បង្គន់
- ស្តារផ្លូវលំជនបទឡើងវិញប្រវែង ៣០០គីឡូម៉ែត្រ
- បង្កលក្ខណៈងាយស្រួល ក្នុងការប្រើប្រាស់សេវាឥណទាន : ជួយបង្កលក្ខណៈងាយស្រួលដល់កសិករចំនួន ១៦.០០០នាក់ក្នុងការប្រើប្រាស់សេវាឥណទាន និងសេវាសន្សំប្រាក់។

**ការប្រើប្រាស់ដី សំរាប់បង្កបង្កើនផល និងហេដ្ឋារចនាសម្ព័ន្ធសង្គមប្រកបដោយសុវត្ថិភាព និងជាអចិន្ត្រៃ:**

- ផ្ទៃដីចំនួន៣០០ហិកតា ត្រូវបានសំអាតគ្រាប់មីនដោយគំរោង
- កសិករចំនួន ៨០%ដែលបានចូលរួមក្នុងកម្មវិធីអភិវឌ្ឍន៍ចំរុះ បានទទួលកម្មសិទ្ធិដីធ្លី ដោយមានការសម្របសម្រួលពីគំរោង
- បើកយុទ្ធនាការផ្សព្វផ្សាយពីគ្រោះថ្នាក់ដោយសារគ្រាប់មីននៅនឹង កន្លែង រយៈពេល ១៨ខែ។

**រចនាសម្ព័ន្ធតាមលំដាប់ថ្នាក់របស់គំរោងអេកូសន:**

**នៅថ្នាក់ជាតិ :**

- គណៈកម្មាធិការដឹកនាំគំរោងមាន: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងមហាផ្ទៃ ក្រសួងធនធានទឹក និង ឧតុនិយម និង ក្រសួងកិច្ចការនារី ព្រមទាំងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ (ជាក្រសួងសហការ)។
- ក្រុមការងារគំរោងអេកូសន (អ្នកអនុវត្ត)។

**នៅថ្នាក់ខេត្ត :**

- ក្រុមការងារបច្ចេកទេស នៅក្នុងគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត
- ក្រុមការងារគំរោងថ្នាក់ខេត្ត(ជាអ្នកអនុវត្ត) ។

